# កិច្ចព្រមព្រៀង

# រវាង

# រាជរដ្ឋាភិបាលកម្ពុជា

# និង

# រដ្ឋាភិបាលនៃសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់

# ស្តីពី

# កិច្ចសហប្រតិបត្តិការហិរញ្ញវត្ថុ

# ឆ្នាំ ២០០៩

# រាជរដ្ឋាភិបាលកម្ពុជា

# និង

# រដ្ឋាភិបាលនៃសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់

ក្នុងស្មារតីទំនាក់ទំនងជាមិត្តភាពដែលមានកន្លងមករវាងសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ និងព្រះរាជាណាចក្រកម្ពុជា ក្នុងបំណងពង្រឹង និងរឹតទំនាក់ទំនងជាមិត្តភាពតាមរយៈកិច្ចសហប្រតិបត្តិការហិរញ្ញវត្ថុ ក្នុងស្មារតីភាពជាដៃគូ កិច្ចព្រមព្រៀងនេះ បង្កើតជាមូលដ្ឋានគ្រឹះនៃការថែរក្សាទំនាក់ទំនងនោះ

ក្នុងគោលបំណងដើម្បីរួមចំណែកដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា

យោងកំណត់ហេតុកិច្ចចរចារវាងរដ្ឋាភិបាលទាំងពីរនៅទីក្រុងភ្នំពេញ ថ្ងៃទី១៦ ខែតុលា ឆ្នាំ២០០៩

បានព្រមព្រៀងគ្នាដូចតទៅ:

## មាត្រា ១

(១) រដ្ឋាភិបាលនៃសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ នឹងជួយដល់រាជរដ្ឋាភិបាលកម្ពុជា ឱ្យទទួលបាន ពី " សាជីវកម្មឥណទានទីតិសម្បទា "(Kreditanstalt für Wiederaufbau - KfW) នូវការផ្តល់វិភាគទានហិរញ្ញវត្ថុ ជាទឹកប្រាក់សរុប ១៩.០០០.០០០ អឺរ៉ូ (ដប់ប្រាំបួនលានអឺរ៉ូ) សម្រាប់គម្រោងដូចខាងក្រោម:

១-កម្មវិធីការពារសុខភាពសង្គម ដំណាក់កាលទី២ (Social Health Protection II) មានទឹកប្រាក់ដល់ត្រឹម ៦.០០០.០០០ អឺរ៉ូ (ប្រាំមួយលានអឺរ៉ូ)

២-ហិរញ្ញប្បទានសម្រាប់គម្រោងការអភិវឌ្ឍន៍សេដ្ឋកិច្ចតំបន់ (Regional Economic Development) មានទឹកប្រាក់ដល់ត្រឹម ៦.០០០.០០០ អឺរ៉ូ (ប្រាំមួយលានអឺរ៉ូ)

៣-កម្មវិធីហេដ្ឋារចនាសម្ព័ន្ធជនបទ ដំណាក់កាលទី២ (Rural Infrastructure Programme II) មានទឹកប្រាក់ដល់ត្រឹម ៧.០០០.០០០ អឺរ៉ូ (ប្រាំពីរលានអឺរ៉ូ) ។

ប្រសិនបើការសិក្សាត្រូវបានរកឃើញថា គម្រោងទាំងនេះមានគុណសម្បត្តិគ្រប់គ្រាន់សម្រាប់ជំរុញការអនុវត្តន៍ ។

(២) គម្រោងដែលបានចែងដូចក្នុងកថាខ័ណ្ឌទី (១) ខាងលើ អាចនឹងត្រូវជំនួសដោយគម្រោងផ្សេងៗទៀត ប្រសិនបើ រដ្ឋាភិបាលនៃសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ និងរាជរដ្ឋាភិបាលកម្ពុជាមានការឯកភាពគ្នា ។

(៣) កិច្ចព្រមព្រៀងនេះនឹងត្រូវអនុវត្តផងដែរនៅថ្ងៃក្រោយ បើរដ្ឋាភិបាលនៃសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ ផ្តល់លទ្ធភាពឱ្យរាជរដ្ឋាភិបាលកម្ពុជា ទទួលបានវិភាគទានហិរញ្ញវត្ថុពី KfW សម្រាប់ត្រៀម រៀបចំគម្រោងដែលចែងក្នុងកថាខ័ណ្ឌ (១) ខាងលើ ឬសម្រាប់ចូលរួមចាត់វិធានការចាំបាច់ដើម្បីអនុវត្ត និង គាំទ្រគម្រោងដែលចែងក្នុងកថាខ័ណ្ឌ (១) ខាងលើ ។

## មាត្រា ២

(១) ការប្រើប្រាស់ចំនួនទឹកប្រាក់ដែលបានចែងក្នុងមាត្រា ១ (១) នៃកិច្ចព្រមព្រៀងនេះ និងល័ក្ខខ័ណ្ឌផ្តល់ជូន ក៏ដូចជានីតិវិធីសម្រាប់ផ្តល់កិច្ចសន្យា នឹងត្រូវគ្រប់គ្រងដោយកិច្ចសន្យានានាដែលចុះហត្ថលេខារវាង KFW និង អ្នកទទួលវិភាគទានហិរញ្ញវត្ថុ ដែលជាកម្មវត្ថុស្ថិតនៅក្រោមអំណាចនៃច្បាប់ និងលិខិតបទដ្ឋាននានារបស់ សាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ ។

(២) ការប្តេជ្ញាផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការដែលមានចំនួនដូចបានចែងក្នុងមាត្រា ១ (១) នៃកិច្ចព្រមព្រៀង នេះនឹងអស់សុពលភាព បើកិច្ចព្រមព្រៀងហិរញ្ញប្បទានដែលពាក់ព័ន្ធ មិនបានចុះហត្ថលេខាក្នុងរយៈពេល ប្រាំបីឆ្នាំ ក្រោយឆ្នាំនៃការប្តេជ្ញាត្រូវបានធ្វើឡើង។ ទឹកប្រាក់នៃការប្តេជ្ញានេះមានសុពលភាពដល់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៧ ។

(៣) រាជរដ្ឋាភិបាលកម្ពុជា ដែលមិនមែនជាអ្នកទទួលវិភាគទានហិរញ្ញវត្ថុនេះដោយផ្ទាល់ ត្រូវធានាលើការ សងប្រាក់ទាន់ពេលកំណត់ទៅឱ្យ KfW វិញ ផ្អែកតាមកិច្ចសន្យាហិរញ្ញប្បទាននានាដែលនឹងត្រូវបានចុះហត្ថលេខា ស្របតាម កថាខ័ណ្ឌ (១) ខាងលើ ។

## មាត្រា ៣

រាជរដ្ឋាភិបាលកម្ពុជាត្រូវទទួលបន្ទុកក្នុងការបង់ពន្ធ អាករ និងថ្លៃសេវាសាធារណៈដ៏ទៃផ្សេងទៀត ដែលមាននៅក្នុងព្រះរាជាណាចក្រកម្ពុជា ជំនួសឱ្យ KfW ពាក់ព័ន្ធនឹងការសម្រេច និងការអនុវត្តកិច្ចសន្យានានា ដែលចែងក្នុងមាត្រា ២ (១) នៃកិច្ចព្រមព្រៀងនេះ ។

## មាត្រា ៤

រាជរដ្ឋាភិបាលកម្ពុជាត្រូវអនុញ្ញាតឱ្យអ្នកដំណើរ និងអ្នកផ្គត់ផ្គង់ ជ្រើសរើសសហគ្រាសដឹកជញ្ជូន ដោយសេរីសម្រាប់ការដឹកជញ្ជូនមនុស្ស និងទំនិញតាមសមុទ្រ ឬតាមអាកាស ដែលស្តែងចេញពីការផ្តល់វិភាគទានហិរញ្ញវត្ថុខាងលើ ដោយជៀសវាងពីការដាក់វិធានការណាមួយដែលអាចរារាំងការចូលរួម ឬធ្វើអោយលំបាកដល់ការចូលរួមដោយស្មើភាពគ្នារបស់សហគ្រាសដឹកជញ្ជូនដែលមានទីតាំងធុរៈកិច្ចនៅក្នុងសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ និងផ្តល់ការអនុញ្ញាតចាំបាច់សម្រាប់ការចូលរួមរបស់សហគ្រាសទាំងនោះ ។

## មាត្រា ៥

កិច្ចព្រមព្រៀងនេះ នឹងចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ មាន ២ ច្បាប់ដើម ដោយមួយច្បាប់មានបីភាសាគឺ ភាសាខ្មែរ អាល្លឺម៉ង់ និង អង់គ្លេស អត្ថបទទាំង ៣ ភាសានេះមានតំលៃដូចគ្នា ។ ក្នុងករណីការបកប្រែមិនស្របមតិគ្នារវាងអត្ថបទ ភាសាអាល្លឺម៉ង់ និងខ្មែរ នោះអត្ថបទភាសាអង់គ្លេសនឹងត្រូវទុកជាបានការ ។

| | |
|---|---|
| **តំណាង** | **តំណាងរដ្ឋាភិបាលនៃ** |
| **រាជរដ្ឋាភិបាលកម្ពុជា** | **សាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់** |